ក្រសួងអប់រំរដ្ឋ NSW

# ការចូលប្រើប្រាស់ NSWEduChat ដោយសិស្ស

ព័ត៌មានសម្រាប់ឪពុកម្ដាយ និងអ្នកថែទាំ

**NSWEduChat គឺជាឧបករណ៍បញ្ញាសិប្បនិមិត្តមួយដែលរចនាដោយ និងជាកម្មសិទ្ធរបស់អប់រំក្រសួង រដ្ឋ NSW (NSW Department of Education)។ វាត្រូវបានរចនាឡើងដើម្បីជាឧបករណ៍ដែលមានសុវត្ថិភាព សម្រាប់ការអប់រំ ផុតពីគ្រោះថ្នាក់ និងមានលក្ខណៈឯកជន។**

## ការចូលប្រើប្រាស់ NSWEduChat ដោយសិស្ស

សិស្សនៅថ្នាក់ទី 5 ដល់ថ្នាក់ទី 12 នឹងទទួលបានការចូលប្រើប្រាស់ NSWEduChat នៅត្រីមាសទី 4 ឆ្នាំ 2025។

## សុវត្ថិភាពនៃសិស្សដែលប្រើប្រាស់ NSWEduChat

ទិន្នន័យ NSWEduChat ត្រូវបានធានា។ ទិន្នន័យទាំងអស់ស្ថិតនៅក្នុងក្រសួង។ នេះមានន័យ ថាសិស្សអាចបញ្ចូលកិច្ចការ និងព័ត៌មានកំណត់អត្តសញ្ញាណផ្ទាល់ខ្លួនរបស់ពួកគេដោយសុវត្ថិភាពទៅក្នុង NSWEduChat។

## ការរចនាសម្រាប់ការអប់រំនៃ NSWEduChat

NSWEduChat មិនគ្រាន់តែផ្ដល់ចម្លើយពេញលេញចំពោះសំណួរនានានោះទេ។ វាឆ្លើយតបទៅសិស្សដោយសួរសំណួរបើកចំហដែលមិនកំណត់។ នេះលើកទឹកចិត្តសិស្សឱ្យស្វែងយល់ និងចែករំលែកគំនិត ហើយនិងហេតុផលរបស់ពួកគេ។ NSWEduChat ប្រើតែអត្ថបទប៉ុណ្ណោះ។ នេះមានន័យថា វាមិនអាចផលិតប្រព័ន្ធផ្សព្វផ្សាយដូចជារូបភាព វីដេអូ ឬតន្ត្រីបានទេ។

## ការប្រើប្រាស់ NSWEduChat សម្រាប់ជំនួយជាមួយកិច្ចការសាលាគ្រូដាក់ឱ្យធ្វើនៅផ្ទះ និងកិច្ចការវាយតម្លៃនានា

ប្រសិនបើសាលារៀនណែនាំថា NSWEduChat អាចប្រើបានសម្រាប់កិច្ចការសាលាគ្រូដាក់ឱ្យធ្វើនៅផ្ទះ និងកិច្ចការវាយតម្លៃនានា សិស្សគួរជូនដំណឹងដល់គ្រូរបស់ពួកគេ ប្រសិនបើពួកគេបានប្រើ NSWEduChat ក្នុងការបំពេញកិច្ចការ។ នេះរួមបញ្ចូលទាំងការប្រើប្រាស់ NSWEduChat សម្រាប់កិច្ចការនានាដូចជា ប៉ុន្តែមិនកំណត់ចំពោះ ការសង្ខេបកំណត់ចំណាំការសិក្សា និយមន័យនៃពាក្យគន្លឹះ ឬការធ្វើរចនាសម្ព័ន្ធអត្ថបទ។ សាលារៀនគួរប្រាស្រ័យទាក់ទងដោយសមហេតុផល ពីរបៀបដែលសិស្សអាចជូនដំណឹងដល់គ្រូរបស់ពួកគេ។

## ការចូលប្រើប្រាស់ NSWEduChat នៅផ្ទះ

សិស្សអាចចូលប្រើប្រាស់ NSWEduChat នៅផ្ទះតាមរយៈ៖

- វិបផតថលសិស្សនៅតាមគេហទំព័រ https://portal.education.nsw.gov.au/
- ដោយផ្ទាល់តាមរយៈ chat.education.nsw.gov.au

សិស្សនឹងចាំបាច់ត្រូវបើកចូលដោយប្រើការបើកចូល NSW Department of Education របស់ពួកគេ។ មានតែសិស្សដែលបានបើកចូលប៉ុណ្ណោះគួរប្រើ NSWEduChat។

ប្រសិនបើអ្នកចង់ពិភាក្សាពីចំណុចណាមួយនៃឧបករណ៍នេះ សូមទាក់ទងមកនាយកសាលា។

សម្រាប់ព័ត៌មានបន្ថែម និងការចូលទៅកាន់ NSWEduChat parental privacy notice (សេចក្ដីជូនដំណឹងអំពីឯកជនសម្រាប់ឪពុកម្ដាយ NSWEduChat) សូមចូលមើល៖ ការចូលប្រើប្រាស់ NSWEduChat ដោយសិស្ស

## សេវាកម្មបកប្រែផ្ទាល់មាត់តាមទូរសព្ទ (TIS): 131 450

ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែផ្ទាល់មាត់ សូមទូរសព្ទទៅ TIS ហើយប្រាប់ពីភាសាមួយណាដែលអ្នកត្រូវការ និងលេខទូរសព្ទដែលអ្នកចង់ហៅ។ ការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយក្នុងការសន្ទនារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។